# កំណត់សារព័ត៌មាន

## សហភាពអន្តរសភា(IPU) ស្វាគមន៍ការដោះលែងតំណាងរាស្ត្រកម្ពុជា និងកិច្ចព្រមព្រៀងនយោបាយ រវាងរដ្ឋាភិបាល និងគណបក្សប្រឆាំង

ទីក្រុងហ្សឺណែវ, ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤

សហភាពអន្តរសភា(IPU) បានស្វាគមន៍ការដោះលែងតំណាងរាស្ត្រគណបក្សប្រឆាំងនៃប្រទេសកម្ពុជាចំនួនប្រាំពីររូប ដែលបានចាប់ខ្លួនកាលពីសប្តាហ៍មុន ក្នុងបទចោទប្រកាន់ពីការបះបោរ ពាក់ព័ន្ធនឹងតួនាទីរបស់ខ្លួន ក្នុងការតវ៉ាដោយហិង្សា នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែកក្កដា។

ទោះជាយ៉ាងណាក៏ដោយ សហភាពអន្តរសភា(IPU) គូសបញ្ជាក់ជាថ្មីនូវការអំពាវនាវរបស់ខ្លួនដល់អាជ្ញាធរកម្ពុជាឲ្យគោរពយ៉ាងពេញលេញនូវនីតិវិធីត្រឹមត្រូវ និងទម្លាក់ការចោទប្រកាន់ទាំងអស់ភ្លាមៗ ប្រឆាំងនឹងតំណាងរាស្ត្រទាំងនោះ ល្គឹកណាគ្មានភស្តុតាងរឹងមាំទេនោះ។ យោងតាមប្រភពរបស់សហភាពអន្តរសភា(IPU) តំណាងរាស្ត្រទាំងនោះ ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ប៉ុន្តែនៅតែត្រូវប្រឈមនឹងការជំនុំជម្រះក្តីរបស់តុលាការជាដដែល នៅពេលក្រោយ។

ការដោះលែងនេះ បានកើតឡើងភ្លាមៗបន្ទាប់ពីការប្រកាសអំពីកិច្ចព្រមព្រៀងមួយ ដែលបានទទឹងរង់ចាំជាយូរមកហើយ រវាងរដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រីហ៊ុនសែន និងមេដឹកនាំគណបក្សប្រឆាំង គឺលោក សម រង្ស៊ី ដើម្បីបញ្ចប់ភាពជាប់គាំងនយោបាយអស់រយៈពេលជិតមួយឆ្នាំ នៅក្នុងប្រទេសនេះ។

កាលពីសប្តាហ៍មុន សហភាពអន្តរសភា(IPU) បានអំពាវនាវឲ្យដោះលែងជាបន្ទាន់នូវតំណាងរាស្ត្រទាំងប្រាំពីររូបដែលបានចាប់ខ្លួន ក្រោយពីមានបាតុកម្មមួយ ជំទាស់ទៅនឹងការបន្តបិទទីតាំងតែមួយគត់សម្រាប់ធ្វើការតវ៉ានៅរាជធានីភ្នំពេញ គឺទីលានប្រជាធិបតេយ្យ បានប្រែទៅជាអំពើហឹង្សា។ កងសន្តិសុខ និងអ្នកគាំទ្រគណបក្សប្រឆាំងជាច្រើននាក់ ត្រូវបានរងរបួស។

ករណីនៃតំណាងរាស្ត្រទាំងប្រាំពីររូបនេះ ត្រូវបានបញ្ជូនទៅគណៈកម្មាធិការសិទ្ធិមនុស្សនៃសមាជិកសភារបស់សហភាពអន្តរសភា(IPU) ដែលនឹងធ្វើការស៊ើបអង្កេត ផ្អែកលើព័ត៌មានដែលភាគីទាំងពីរបានផ្តល់ឲ្យ ពីអាជ្ញាធរ និងពីអ្នកប្តឹង។

សហភាពអន្តរសភា(IPU) ស្វាគមន៍ផងដែរ ចំពោះកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល និងគណបក្សប្រឆាំងដ៏ធំមួយនេះ គឺគណបក្សសង្គ្រោះជាតិ (CNRP) ដែលបានព្រមព្រៀងគ្នា បញ្ចប់ការធ្វើពហិការសភា គឺមួយឆ្នាំបន្ទាប់ពីមានទំនាស់អំពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ បើតាមលទ្ធផលជាផ្លូវការ គណបក្សសង្គ្រោះជាតិ(CNRP) ទទួលបានអាសនៈចំនួន៥៥ នៅក្នុងរដ្ឋសភា។

ជាការផ្លាស់ប្តូរ រដ្ឋាភិបាលបានទទួលយកការរុះរើក្បាលម៉ាស៊ីនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលត្រូវបានចោទប្រកាន់ដោយគណបក្សប្រឆាំងពីការលួចបន្លំសន្លឹកឆ្នោត គាំទ្រដល់គណបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជា (CPP)។ ភាគីទាំងពីរបានប្តេជ្ញាចិត្តដោះស្រាយទំនាស់នៅក្នុងរដ្ឋសភា។

"នេះជាជំហានមួយក្នុងទិសដៅដ៏ត្រឹមត្រូវ។ រដ្ឋសភាគឺជាកន្លែងធ្វើការរួមគ្នា ដើម្បីរកដំណោះស្រាយចំពោះទំនាស់នយោបាយ តាមរយៈការសន្ទនាគ្នា។ សហភាពអន្តរសភា(IPU) ត្រៀមខ្លួនជាស្រេច ដើម្បីជួយក្នុងកិច្ចការនេះ ដើម្បីឲ្យសភាកម្ពុជាអាចបំពេញអាណត្តិដែលប្រជាជនកម្ពុជាបានប្រគល់ឲ្យ" នេះបើតាមប្រសាន៍របស់ ម៉ាទីន ជុនហ្គុង អគ្គលេខាធិការនៃសហភាពអន្តរសភា(IPU)។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖ ជេមីនី ផាន់ឌីយ៉ា តាមរយៈទូរស័ព្ទលេខ +៤១ ២២ ៩១៩ ៤១៥៨/+៤១ ៧៩ ២១៧ ៣៣៧៤ អ៊ីម៉ែល: jep@ipu.org ឬ ហ្វ្រឺណិនដូ ភូជុល +៤១ ២២ ៩១៩ ៤១៣៩ អ៊ីម៉ែល: fp@ipu.org*